**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកណ្ដាល**

-សំណុំរឿងព្រហ្មទណ្ឌ លេខ: **១០៣៦ អក**
ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០០៧
-សាលក្រមលេខ៖ **២២ (ឃ)**
ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០២២

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តកណ្ដាល

-បានបើកសវនាការជំនុំជម្រះជាសាធារណៈ នៅសាលាដំបូងខេត្តកណ្ដាល នៅថ្ងៃទី០៣ ខែមីនា ឆ្នាំ២០២២ ដោយមាន សមាសភាពដូចតទៅ:

### សមាសភាពជំនុំជម្រះ

លោកស្រី [redacted] ចៅក្រមសាលាដំបូងខេត្តកណ្ដាល

### តំណាងអយ្យការ

លោក [redacted] ព្រះរាជអាជ្ញារង អមសាលាដំបូងខេត្តកណ្ដាល

### ក្រឡាបញ្ជីសវនាការ

លោកស្រី [redacted] ក្រឡាបញ្ជី សាលាដំបូងខេត្តកណ្ដាល

**ដើម្បីជំនុំជម្រះ**បណ្ដឹងទាស់លើសាលក្រមលេខ: **០១ (ណ)** ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០១២ សំណុំរឿងព្រហ្មទណ្ឌលេខ: **១០៣៦ អក** ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០០៧ ដែលមានជនជាប់ចោទដូចខាងក្រោម ៖

-ឈ្មោះ [redacted] **ស៊ុយ** ភេទ្រុស អាយុ ២២ឆ្នាំ ជនជាតិខ្មែរ មុខរបរមិនពិតប្រាកដ ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្ននៅភូមិ[redacted]ខេត្តកណ្ដាល ឪពុកឈ្មោះ [redacted] សុង (រ) ម្ដាយឈ្មោះ[redacted]ពៅ (រ) នៅលីវ ទោសពីមុន គ្មាន ។ (ក្រៅឃុំ)

អមដោយមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] **ស៊ុយ** ។

ជាប់ចោទពីបទ: **បង្ករបួសដោយចេតនា** ប្រព្រឹត្តនៅភូមិស្វាយកណ្ដាល ឃុំព្រែកថ្មី ស្រុកកោះធំ ខេត្តកណ្ដាល កាលពីថ្ងៃទី១១ ខែតុលា ឆ្នាំ២០០៧ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៤១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] **ថាច** ភេទប្រុស អាយុ ២០ឆ្នាំ ជនជាតិខ្មែរ មុខរបរកសិករ ទីលំនៅបច្ចុប្បន្ននៅភូមិកំពង់ស្វាយលើ ឃុំព្រែកថ្មី ស្រុកកោះធំ ខេត្តកណ្ដាល ។

### អង្គហេតុមានដូចតទៅ

កាលនៅថ្ងៃទី១១ ខែតុលា ឆ្នាំ២០០៧ វេលាម៉ោង ១៥ និង ០០នាទី ឈ្មោះ ភន ថាច បានមកអង្គុយលេងនៅកន្លែងលក់ពងទាកូនរបស់ឈ្មោះ [redacted] មុំ ស្ថិតនៅភូមិស្វាយកណ្ដាល ឃុំព្រែកថ្មី ស្រុកកោះធំ ខេត្តកណ្ដាល ក្នុងពេលនោះឈ្មោះ [redacted]ដារិទ្ធ , ឈ្មោះ [redacted] ហ៊ាង , ឈ្មោះ [redacted] ស៊ុយ , ឈ្មោះ [redacted]កុសល , ឈ្មោះ [redacted] ប៉េងឃី , ឈ្មោះ [redacted] លីហ៊ា និងឈ្មោះ [redacted] ហ៊ាប បានត្រឡប់មកពីផឹកស្រាស្រវឹងហើយបានរករឿងឈ្លោះនិងព្រួតវាយទៅលើឈ្មោះ [redacted] ថាច បណ្ដាលឱ្យមានរបួសដល់សន្លប់ ។ ក្រោយពេលកើតហេតុ



Scanned with CamScanner

សមត្ថកិច្ចបានឃាត់ខ្លួនជនល្មើសបានមួយចំនួន និងមួយបានរត់គេចខ្លួន ហើយកសាងសំណុំរឿងបញ្ជូនមកសាលាដំបូងខេត្តកណ្តាលតែម្តង ។

**បានឃើញ** សាលក្រមលេខៈ ០១ (ណ) ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០១២ របស់សាលាដំបូងខេត្តកណ្តាលដែលមានខ្លឹមសារ ៖

**១**-ផ្តន្ទាទោសជនជាប់ចោទ ៖

**ក**-ឈ្មោះ [redacted] **លីហ៊ី** ភេទប្រុស អាយុ ២០ឆ្នាំ ជនជាតិខ្មែរ , ឈ្មោះ [redacted] **ដារិទ្ធ** ភេទប្រុស អាយុ ១៩ឆ្នាំ ជនជាតិខ្មែរ , ឈ្មោះ [redacted] **ហ៊ាង** ភេទប្រុស អាយុ ២០ឆ្នាំ ជនជាតិខ្មែរ , ឈ្មោះ [redacted] **ស៊ុយ** ភេទប្រុស អាយុ ២២ឆ្នាំ ជនជាតិខ្មែរ , ឈ្មោះ [redacted] **កុសល** ភេទប្រុស អាយុ ២៤ឆ្នាំ ជនជាតិខ្មែរ និងឈ្មោះ [redacted] **ហ៊ាប** ភេទប្រុស អាយុ ២០ឆ្នាំ ជនជាតិខ្មែរ ដាក់ពន្ធនាគារក្នុងម្នាក់ៗកំណត់ចំនួន ០១ (មួយ) ឆ្នាំ ។

**ខ**-ឈ្មោះ [redacted] **ប៉េងឃី** ភេទប្រុស អាយុ ២០ឆ្នាំ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេល ០៦ (ប្រាំមួយ) ខែ ។

ពីបទៈ **បង្ករបួសដោយចេតនា** ប្រព្រឹត្តនៅភូមិស្វាយកណ្តាល ឃុំព្រែកថ្មី ស្រុកកោះធំ ខេត្តកណ្តាល កាលពីថ្ងៃទី១១ ខែតុលា ឆ្នាំ២០០៧ តាមបញ្ញត្តិមាត្រា ៤១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល។

**២**-វត្ថុតាងរួមមាន ដំបងឈើមួយចំនួន ទំហំ ១២ សង់ទីម៉ែត្រ ប្រវែង ៥២ សង់ទីម៉ែត្រ តុលាការសម្រេចរឹបអូសបំផ្លាញចោល ។

៣-បង្គាប់ឱ្យជបជាប់ចោទឈ្មោះ [redacted] **ហ៊ាង** , ឈ្មោះ [redacted] **ស៊ុយ** , ឈ្មោះ [redacted] **កុសល** , ឈ្មោះ [redacted] **ប៉េងឃី** , ឈ្មោះ [redacted] **លីហ៊ី** និងឈ្មោះ [redacted] **ហ៊ាប** រួមគ្នាសងសំណងការខូចខាត និងជម្ងឺចិត្តជាប្រាក់ចំនួន **៤,០០០,០០០ (បួនលាន) រៀល** ទៅឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **ថាច** ការទាមទារលើសពីនេះលើកចោល ។

-សាលក្រមនេះជំនុំជំរះ និងប្រកាសជាសាធារណៈនៅថ្ងៃទី១១ ខែមករា ឆ្នាំ២០១២ កំបាំងមុខជនជាប់ចោទ និងមុខដើមបណ្តឹងរដ្ឋប្បវេណី ។

ទុកសិទ្ធិឲ្យប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

**បានឃើញ** ពាក្យសុំប្តឹងទាស់ ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០២២ របស់ឈ្មោះ [redacted] **ស៊ុយ (ជនជាប់ចោទ)** ដែលមានខ្លឹមសារៈ

សុំប្តឹងទាស់ និងសាលក្រមព្រហ្មទណ្ឌកំបាំងមុខលេខៈ **០១ (ណ)** ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០១២ របស់សាលាដំបូងខេត្តកណ្តាល ។

## **នាពេលសវនាការ**

-ពិរុទ្ធជនឈ្មោះ [redacted] **ស៊ុយ** បានឆ្លើយថា ខ្លួនសុំប្តឹងទាស់ ប៉ុន្តែខ្លួនគ្មានឯកសារបញ្ជាក់បន្ថែម ជូនតុលាការពិនិត្យទេ ខ្លួនមិនអាចទទួលនៅសេចក្តីសម្រេចនេះបានទេ ព្រោះនៅពេលកើតហេតុខ្លួនមិនបានវាយទៅលើជនរងគ្រោះនោះឡើយ តែខ្លួនបានទៅជួយឃាត់មិនឱ្យឈ្លោះគ្នា ហើយចំពោះអ្នកវាយជនរងគ្រោះសន្លប់នោះ ខ្លួនមិនបានដឹងទេ ហើយអ្នកណាវាយអ្នកណានោះ ក៏ខ្លួនមិនដឹងទេ ដោយសារពេលនោះមានមនុស្សច្រើន ។ ហើយនៅក្នុងរឿងនេះ ពេលដែលតុលាការធ្វើការជំនុំជម្រះ ខ្លួនមិនបានទទួលដំណឹង គឺកាត់ក្តីដោយកំបាំងមុខខ្លួនទៀត ។ ខ្លួនមិនបានរត់គេចខ្លួនទៅណានោះទេ គឺខ្លួនទៅធ្វើការសំណង់នៅខេត្ត ។ ខ្លួនមិនបានចូលរួមសកម្មភាព ឬឈ្លោះគ្នាជាមួយគេនោះទេ ។ នៅពេលកើតហេតុនោះខ្លួនក៏បាននៅកន្លែងកើត



Scanned with CamScanner

ហេតុដែរ ដោយទៅហូបពងទាកូន ហើយខ្លួនបានចូលទៅបន្ទប់ទឹក ពេលចេញមកវិញក៏ឃើញគេឈ្លោះគ្នាតែម្តង ។

-អំណានចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] **លីហ៊ី** នាពេលសវនាការ នៅថ្ងៃទី១១ ខែតុលា ឆ្នាំ២០០៧ វេលាម៉ោងដប់ជាង ពួកខ្លួនមានគ្នាពី បួននាក់ ទៅ ប្រាំនាក់ ដើរសំដៅទៅរោងកាហ្វេរបស់ឈ្មោះ វ៉ៃ រួចឡើងអង្គុយលើគ្រែមុខរោងកាហ្វេជុំគ្នា ហើយពួកខ្លួនក៏រ៉ៃប្រាក់គ្នាក្នុងម្នាក់ ១០០០០ ៛ (មួយម៉ឺនរៀល) ដើម្បីទិញស្រាបៀរហូបនៅផ្ទះរបស់ឈ្មោះ [redacted] ដារិទ្ធិ ពេលហូបរួចខ្លួនក៏ដើរមកអង្គុយមុខរោងកាហ្វេ រួចបន្តដំណើរទៅច្រៀងខារ៉ាអូខេ ពេលនោះខ្លួនដើរតាមពួកខ្លួនពីក្រោយ ស្រាប់តែពួកខ្លួនបានវាយគ្នាទៅវិញទៅមក នៅខាងមុខផ្ទះច្រៀងខារ៉ាអូខេ ស្ថិតនៅភូមិស្វាយកណ្តាល ឃុំព្រែកថ្មី ស្រុកកោះធំ ខេត្តកណ្តាល នៅវេលាម៉ោង ១៦ ជិតឈានចូលម៉ោង ១៧ ល្ងាច ។ ពេលគេកំពុងតែវាយគ្នានោះ ខ្លួនក៏ស្ទុះចូលទៅឃាត់បានមួយសន្ទុះ ហើយពួកនោះក៏ឈប់វាយគ្នាទៅ ក៏បំបែកគ្នាទៅផ្ទះ ប៉ុន្តែមិនទាន់ដល់ផ្ទះផងត្រូវសមត្ថកិច្ចចាប់ខ្លួនតែម្តង ។ ចំណែកខ្លួនពុំបានវាយគេទេ ពីព្រោះខ្លួនគ្រាន់តែជួយឃាត់ពួកគេតែប៉ុណ្ណោះ ។

-អំណានចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] **ដារិទ្ធិ** នាពេលសវនាការ នៅថ្ងៃទី១១ ខែតុលា ឆ្នាំ២០០៧ វេលាម៉ោង ១១ ជិតថ្ងៃត្រង់ពួកខ្លួនមានគ្នា ចំនួន ០៧នាក់ ព្រមទាំងខ្លួនពេលជួបជុំគ្នាក៏រ៉ៃប្រាក់គ្នា ចំនួន ១០០០០ ៛ (មួយម៉ឺនរៀល) ក្នុងម្នាក់ដើម្បីទិញស្រាបៀរយកមកហូបនៅផ្ទះខ្លួន ពេលហូបស្រាបៀររួច ក៏ដើរទៅរោងកាហ្វេឈ្មោះ វ៉ៃ ពេលជុំគ្នាហើយក៏ដើរឆ្លងផ្លូវថ្នល់ទៅរកច្រៀងខារ៉ាអូខេ មិនទាន់បានច្រៀងផង មិត្តភក្តិខ្លួនក៏ស្ទុះវាយពួកគេហើយពួកគេក៏វាយមកវិញ ពេលនោះខ្លួនស្ទុះវាយគេខុស ហើយវាយគ្នាទៅវិញទៅមក នៅចំណុចលក់ពងទាកូននៅភូមិស្វាយកណ្តាល ឃុំព្រែកថ្មី ស្រុកកោះធំ ខេត្តកណ្តាល នៅវេលាម៉ោងដប់ប្រាំមួយឈានចូលម៉ោងដប់ប្រាំពីរល្ងាច ។ ពេលខ្លួនវាយគ្នាទៅវិញទៅមកអស់មួយសន្ទុះរួចបំបែកគ្នាទៅផ្ទះ ប៉ុន្តែមិនទាន់ដល់ផ្ទះផង ក៏ត្រូវសមត្ថកិច្ចចាប់ឃាត់ខ្លួនតែម្តង ។ ចំណែកឈ្មោះ [redacted] ថាច ខ្លួនពុំបានវាយគេទេ គឺឈ្មោះ [redacted] ឈី , ឈ្មោះ [redacted] , ឈ្មោះ ហ៊ាប ជាអ្នកវាយទៅឈ្មោះ [redacted] ថាច ចំណែកខ្លួនត្រូវគេវាយចំមួយដៃបែកមាត់ខាងស្តាំទៀងផង ។

-អំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **ថាច** បានឆ្លើយថា ថ្ងៃកើតហេតុត្រូវថ្ងៃភ្ជុំបិណ្ឌ ត្រូវថ្ងៃទី១១ ខែតុលា ឆ្នាំ២០០៧ ម៉ោងប្រហែល ០៣ និង ១៥នាទី រសៀល ខ្លួនមានគ្នាបីនាក់ គឺឈ្មោះ [redacted] សុជា , ឈ្មោះ [redacted] សុភី និងខ្លួន ។ ពួកខ្លួនកំពុងនាំគ្នាអង្គុយលេងនៅរោងលក់ពងទាកូនរបស់ឈ្មោះ [redacted] មុំ ស្រាប់តែឈ្មោះ [redacted] ដារិទ្ធិ ហៅ អាគោ , ឈ្មោះ [redacted] ស៊ុយ ហៅ អា ពក , ឈ្មោះ [redacted] ហៀង ហៅ អាកៃ , ឈ្មោះ [redacted] កុសល , ឈ្មោះ [redacted] ប៉េងឃី និងឈ្មោះ ណុយ , ឈ្មោះ [redacted] ហ៊ិ ។ ឈ្មោះ ណុយ និងឈ្មោះ ហ៊ិ នៅភូមិកំពង់ស្វាយលើ ក្រៅពីនេះនៅភូមិកំពង់ស្វាយកណ្តាល។ មុនពេលកើតហេតុពួកវាធ្វើដំណើរពីកើតមក ឃើញពួកខ្លួនអង្គុយនៅរោងលក់ពងទាកូន ក៏នាំគ្នាចូលមកវ៉ៃខ្លួនតែម្តង ខ្លួនអង្គុយលេងនៅទីនោះមិននឹកស្មានថាពួកគេចូលរកវាយខ្លួនទេ ស្មានតែគេនាំគ្នាចូលមកធម្មតា។ អ្នកចូលមកវាយខ្លួនមុនគេឈ្មោះ [redacted] ស៊ុយ បច្ចុប្បន្នរត់គេចខ្លួនបាត់ហើយ ដំបូងវាយខ្លួននិងដៃ តែភ្លាមនោះពួកវារោមខ្លួនជិត មិត្តភក្តិខ្លួនឈ្មោះ ចន សុភី ត្រូវឈ្មោះ ណុយ ចាប់ទុកឱ្យគ្នាវាវាយ តែបានគេនៅជិតនោះចូលទៅជួយឃាត់ ពួកវាវ៉ៃឈ្មោះ [redacted] សុភី ត្រូវបន្តិចដែរ ។ ក្រោយពីខ្លួនរើរួចពីពួកគេព្រួតវាយខ្លួននោះ ខ្លួនបានរត់ទៅលិច តែទាល់និងរបងរោងចក្រ ខ្លួនរត់អត់រួច ត្រូវពួកវាតាមទៅព្រួតវាយម្តងទៀត ខ្លះយកខ្សែក្រវ៉ាត់វាយខ្លួន ខ្លះទៀតវាយខ្លួននិងដំបង ពេលនោះខ្លួនសន្លប់ ពេលដឹងខ្លួននៅមន្ទីរពេទ្យស្រុកកោះធំ ។ ខ្លួនរងគ្រោះបាក់ធ្មេញមុខបី ស្នាមជាំពេញខ្លួន សន្លប់។

-អំណានចម្លើយសាក្សីឈ្មោះ [redacted] **ចាន់ថុល** បានឆ្លើយថា នៅថ្ងៃកើតហេតុនោះ ខ្លួននៅកន្លែងកើតហេតុ ហើយបានចូលទៅជួយឃាត់ទៀតផង ព្រោះកើតហេតុនៅរោងលក់ពងទាកូនបងខ្លួនឈ្មោះ [redacted] មុំ តែ



Scanned with CamScanner

បងស្រីខ្លួនឈ្មោះ [redacted] មុំ គាត់ចេញពីរោងគាត់បាត់ទៅហើយ ទើបមានរឿងវាយតប់កើតឡើង ។ ក្រោយពីមានការវាយតប់រួចខ្លួនបានឮគេនិយាយថា ឈ្មោះ ផន លីហ៊ ពុំបានចូលទៅព្រួតវាយជនរងគ្រោះទេ ឈ្មោះនេះ គាត់តែបានចូលទៅជួយឃាត់ ។ កើតហេតុលើកទីមួយ មានតែម្នាក់ទេ ខ្លួនឃើញឆ្លងផ្ទាល់ទៅវាយជនរងគ្រោះមុនគេ ភ្លាមនោះបានក្រុមគេឆ្លងទៅជួយវាយ ចំណែករឿងរ៉ាវ នៅរបងរោងចក្រនោះខ្លួនអត់ដឹងទេ ។ ចំណែកឈ្មោះ [redacted] ដារិទ្ធិ ក៏បានចូលរួមដែរ តែបានវាយឬមិនបានវាយនោះ ខ្លួនពុំបានដឹងទេ ។

-អំណានចម្លើយសាក្សីឈ្មោះ [redacted] សុភី បានឆ្លើយថា ខ្លួនបានធ្វើដំណើរចេញពីផ្ទះខ្លួននៅភូមិស្វាយលើទៅ មានគ្នាបីនាក់ ពួកខ្លួនទៅអង្គុយនៅរោងលក់ពងទាកូនរបស់ឈ្មោះ មុំ នៅភូមិស្វាយកណ្ដាល ។ ពួកខ្លួនកំពុងអង្គុយលេង ស្រាប់តែមានមនុស្សមួយក្រុមមានគ្នា ០៦ ទៅ ០៧ នាក់ បាននាំគ្នាមកព្រួតគ្នាចោមរោមវាយទៅលើឈ្មោះ [redacted] ថាច នៅហ្នឹងកន្លែងលក់ពងទាកូនតែម្ដង ។ ដំបូងពួកវាវាយនឹងដៃ អត់ទាន់ប្រើអាវុធទេ ក្រោយមកឈ្មោះ [redacted] ថាច បានរត់រួច រត់ទៅលិចកាត់ព្រៃដំឡូង តែដោយទាល់របងរោងចក្រ ធ្វើឱ្យឈ្មោះ [redacted] ថាច រត់មិនរួច ក្រុមជនល្មើសតាមទាន់ឈ្មោះ [redacted] ថាច ហើយខ្លះយកខ្សែក្រវ៉ាត់ ខ្លះកាន់ដំបងវាយលើឈ្មោះ [redacted] ថាច រហូតដល់សន្លប់នៅកន្លែងកើតហេតុតែម្ដង ។ ខ្លួនឃើញឈ្មោះ ហៀប ចូលវាយមុនគេ បន្ទាប់មកឈ្មោះ [redacted] ដារិទ្ធិ ហៅ គោ , ឈ្មោះ យី , ឈ្មោះ សល់ , ឈ្មោះ ពក , ឈ្មោះ កែ នៅភូមិស្វាយកណ្ដាល , ឈ្មោះ ណុយ , ឈ្មោះ ហ៊ា នៅភូមិស្វាយលើ ឃុំព្រែកថ្មី ស្រុកកោះធំ ឈ្មោះទាំងនេះហើយដែលបានព្រួតវាយទៅលើឈ្មោះ [redacted] ថាច ។ ចំណែកខ្លួនត្រូវឈ្មោះ ណុយ ចាប់កាន់ដៃខ្លួនទៅក្រោយ ទុកឱកាសឱគ្នាគេវាយ តែជនល្មើសពុំទាន់បានវាយទេ ត្រូវមានគេចូលទៅឃាត់ទៅ ។

-អំណានចម្លើយសាក្សីឈ្មោះ [redacted] សុផា បានឆ្លើយថា នៅថ្ងៃទី១១ ខែតុលា ឆ្នាំ២០០៧ វេលាម៉ោងប្រមាណ ១៤ និង ០០នាទី ខ្លួនបានចេញពីផ្ទះមកលេងផ្ទះ ឈ្មោះ [redacted] ថាច និងឈ្មោះ [redacted] សុភី នៅភូមិកំពង់ស្វាយលើ ឃុំព្រែកថ្មី រួចនាំគ្នាមកអង្គុយលេងនៅរោងលក់ពងទាកូនរបស់ឈ្មោះ [redacted] មុំ ភេទស្រី នៅភូមិស្វាយកណ្ដាល ឃុំព្រែកថ្មី ស្រុកកោះធំ ខេត្តកណ្ដាល លុះនៅវេលាម៉ោងប្រមាណ ដប់ប្រាំ ថ្ងៃដដែល មានមនុស្សមួយក្រុមមានគ្នាប្រមាណប្រាំមួយទៅ ប្រាំពីរនាក់ ខ្លះមានដំបង អ្នកខ្លះ ដៃទទេមកវាយឈ្មោះ [redacted] ថាច កំពុងអង្គុយលេងជាមួយខ្លួន ឃើញដូចនេះខ្លួនក៏ស្ទុះចូលឃាត់ក្រុមពួកនោះ ក៏វាយខ្លួនទៀតត្រូវក្បាល និងចុងចិញ្ចើមពីរទៅបីដៃ ខ្លួនក៏រត់គេច ឯរឿងយ៉ាងណាទៀតខ្លួនពុំបានដឹងទេ មួយសន្ទុះក្រោយមកទើបលឺគេនិយាយថា ក្រុមនោះវាយឈ្មោះ [redacted] ថាច ដួលសន្លប់ ខ្លួនក៏មកមើលឈ្មោះ [redacted] ថាច ឃើញគេបីដាក់លើគ្រែសន្លប់ពុំដឹងខ្លួន ហើយយកមកមន្ទីរពេទ្យស្រុកកោះធំ ។ ក្រុមដែលវាយខ្លួន និងវាយឈ្មោះ [redacted] ថាច គឺខ្លួនពុំបានស្គាល់ឈ្មោះទេ គឺស្គាល់មុខ ហើយគេហៅងាវាថា អាតោ នៅភូមិកំពង់ស្វាយកណ្ដាល ឃុំព្រែកថ្មី ស្រុកកោះធំ ក្រៅពីនេះខ្លួនពុំបានស្គាល់អ្នកណាទេ ។

-តំណាងអយ្យការធ្វើសេចក្ដីសន្និដ្ឋានថាៈ ក្រោយពីបានពិនិត្យសំណុំរឿងចប់សព្វគ្រប់ និងបានស្ដាប់ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ស៊ុយ ព្រមទាំងភស្តុតាងផ្សេងៗមក អាចបញ្ជាក់បានថា ជនជាប់ចោទឈ្មោះ [redacted] ស៊ុយ ពិតជាបានវាយទៅលើជនរងគ្រោះបណ្ដាលអោយមានរបួស ពិតប្រាកដមែន ។ ហេតុដូច្នេះតំណាងអយ្យការសុំតម្កល់សាលក្រមដើមទុកជាបានការដដែល ។

-មេធាវី [redacted] ជាមេធាវីការពារសិទ្ធឱ្យពិរុទ្ធជនឈ្មោះ [redacted] ស៊ុយ បានធ្វើសេចក្ដីសន្និដ្ឋានថាក្នុងខ្លួនជាមេធាវីការពារសិទ្ធិ និងតំណាងឱ្យជនជាប់ចោទឈ្មោះ [redacted] ស៊ុយ ហៅ [redacted] វ៉ាន់ស៊ុយ តាមការពិនិត្យសិក្សាសំណុំរឿង និងការសួរដេញដោលនាពេលសវនាការ ខ្លួនសូមធ្វើការបដិសេធចំពោះការចោទប្រកាន់មកលើកូនក្ដីខ្លួន ពីបទៈ បង្ករបួសដោយចេតនា ទាំងស្រុងដោយហេតុថា ៖



Scanned with CamScanner

-ចំពោះពាក្យបណ្ដឹងដែលបានប្ដឹងកូនក្ដីខ្លួនកាលពីថ្ងៃទី១១ ខែតុលា ឆ្នាំ២០០៧ របស់ឈ្មោះ [redacted] ស្រី ត្រូវជាបងរបស់ឈ្មោះ [redacted] ថាច ថាកូនក្ដីខ្លួនបានវាយទៅលើឈ្មោះ [redacted] ថាច ដែលជាជនរងគ្រោះ បណ្ដាលឱ្យមានរបួសដល់សន្លប់នោះ គឺមិនពិតដូចការចោទប្រកាន់ឡើយ នៅថ្ងៃកើតហេតុកូនក្ដីខ្លួនក៏បាន បញ្ជាក់ផងដែរថា កូនក្ដីខ្លួនគាត់ និងមិត្តភក្ដិបាននាំគ្នាទៅរោងការហ្វេទល់មុខរោងលក់ពងទាកូនរបស់ឈ្មោះ មុំ ដើម្បីអង្គុយលេងមួយសន្ទុះខ្លួនក៏ដើរទៅរកកន្លែងនោមនៅក្បែរនោះ ហើយក៏មានអ្នកខ្លះដើរចេញពីរោងការ ហ្វេនេះដែរ ។ បន្ទាប់ពីកូនក្ដីខ្លួនមកពីនោមវិញ ស្រាប់តែមានការស្រែកឆោឡោ ក្នុងនោះកូនក្ដីខ្លួនឃើញមាន ឈ្មោះ [redacted] ដារិទ្ធិ និងអ្នកផ្សេងទៀតជាមួយឈ្មោះ [redacted] ថាច កំពុងតែមានការប្រតាយប្រតប់គ្នាទៅវិញទៅមក នៅពេលនោះកូនក្ដីខ្លួនក៏បានទៅស្រែកសួរនាំថា មានរឿងអ្វីបានជាគ្នា ហើយកូនក្ដីខ្លួនក៏បានចូលឃាត់ពួកគេ ដែរតែពុំមានអ្នកស្ដាប់ មិនត្រឹមតែប៉ុណ្ណោះថែមទាំងច្រានកូនក្ដីខ្លួន បណ្ដាលឱ្យដួលទៀតផង ឃើញសភាព ដូចនោះកូនក្ដីខ្លួនក៏ចាកចេញពីកន្លែងកើតហេតុតែម្ដងទៅ ។

-ផ្អែកតាមចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] ថាច បានឆ្លើយនៅដំណាក់កាលមន្ត្រីនគរបាល យុត្តិធម៌ថា ខ្លួន និងមិត្តភិក្តឈ្មោះ [redacted] សុភី និងឈ្មោះ [redacted] សុជា បាននាំគ្នាទៅអង្គុយលេងនៅរោងពង ទាកូនរបស់ឈ្មោះ [redacted] មុំ មានជនមួយក្រុមមានឈ្មោះ [redacted] ដារិទ្ធ ហៅ តោ , ឈ្មោះ ឃី , ឈ្មោះ កែ , ឈ្មោះ សល់ , ឈ្មោះ [redacted] លីហ៊ី , ឈ្មោះ ហ៊ាប , ឈ្មោះ ពុយ , ឈ្មោះ ពក និងមនុស្សពីរបីនាក់ទៀតខ្លួនពុំ ស្គាល់ បន្តិចក្រោយមកឈ្មោះ [redacted] ដារិទ្ធ ហៅ តោ , ឈ្មោះ ឃី , ឈ្មោះ កែ , ឈ្មោះ ហ៊ាប កាន់ដំបងម្នាក់ មួយមកវាយខ្លួនដោយពុំដឹងមូលហេតុ ។ យោងតាមចម្លើយរបស់ជនរងគ្រោះនេះបានឱ្យឃើញថា កូនក្ដីខ្លួន ឈ្មោះ [redacted] ស៊ុយ ពិតជាពុំបានប្រព្រឹត្តអំពើបង្ករបួសស្នាមមកលើជនរងគ្រោះឡើយ និងពុំមានវត្តមាននៅក្នុង ពេលនោះផងដែរ ។

ដូចនេះឃើញថា ពុំមានភស្តុតាងជាក់បន្ទុកណាមួយមកបញ្ជាក់ឱ្យច្បាស់ថា បានឃើញកូនក្ដីខ្លួន ផ្ទាល់ជាជនបង្ក ដែលបានប្រព្រឹត្តអំពើបង្ករបួសស្នាមលើឈ្មោះ [redacted] ថាច ដូចការចោទប្រកាន់មកលើកូនក្ដី ខ្លួនឡើយ ។

-តំណាងអយ្យការបានធ្វើការចោទប្រកាន់មកលើកូនក្ដីខ្លួន ដោយយោងតាមដីកាបញ្ជូនរឿងឱ្យស៊ើប សួរលេខៈ ៧៩៦ ដកសស ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០០៧ ដែលបានសម្រេចចោទប្រកាន់លើកូនក្ដីខ្លួន ឃើញថា កូនក្ដីខ្លួនពិតជាទទួលរងនូវភាពអយុត្តិធម៌ជាខ្លាំង ព្រោះថានៅថ្ងៃកើតហេតុ ពេលដែលកំពុងមាន ការប្រតាយប្រតប់គ្នានោះកូនក្ដីខ្លួនពុំបានចូលរួមឡើយ នៅពេលនោះកូនក្ដីខ្លួនកំពុងតែ ទៅនោមនៅក្បែរនោះ ទេ ពេលមកវិញឃើញមានការប្រតាយប្រតប់គ្នារួចទៅហើយ ហើយកូនក្ដីខ្លួនក៏បានទៅចូលឃាត់ថែមទៀត ផង ។

-ផ្អែកតាមចម្លើយរបស់សាក្សីឈ្មោះ [redacted] សុភី នៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ ដែលជាមិត្ត ភក្ដិជនរងគ្រោះនៅកន្លែងកើតហេតុផ្ទាល់ជាមួយឈ្មោះ [redacted] សុជា និងឈ្មោះ [redacted] ថាច ក៏បានឆ្លើយបញ្ជាក់ ផងដែរថា នៅពេលខ្លួនកំពុងអង្គុយលេងនៅរោងកាហ្វេមុខរោងរបស់ខ្លួន មានឈ្មោះ [redacted] ដារិទ្ធ ហៅ អាតោ , ឈ្មោះ ហ៊ាប , ឈ្មោះ កែ និងឈ្មោះ ឃី បានកាន់ដំបងឈើម្នាក់មួយដើរឆ្លងផ្លូវតម្រង់មកពួកខ្លួន ពេលនោះ អ្នកទាំងបួននាក់បានមកវាយឈ្មោះ [redacted] ថាច ដែលចម្លើយបានបញ្ជាក់ឱ្យឃើញថា កូនក្ដីខ្លួនពុំមានវត្តមាន ក្នុងការប្រព្រឹត្តអំពើបង្ករបួសស្នាមមកលើជនរងគ្រោះឡើយ ។

-ផ្អែកតាមចម្លើយរបស់សាក្សីឈ្មោះ [redacted] សុជា ជាមិត្តភក្ដិជនរងគ្រោះនៅកន្លែងកើតហេតុផ្ទាល់ ក៏ បានឆ្លើយបំភ្លឺថា នៅថ្ងៃកើតហេតុពេលក្រុមខ្លួនទាំងបីនាក់ កំពុងអង្គុយលេងនៅរោងលក់ពងទាកូនរបស់

ឈ្មោះ [redacted] មុំ ឃើញមានជនមួយក្រុមខ្លះមានដំបង ខ្លះដៃទទេ មកវាយឈ្មោះ [redacted] ថាច កំពុងអង្គុយលេងជាមួយខ្លួន ឃើញដូចនេះខ្លួនក៏ចូលឃាត់ ហើយក៏ត្រូវគេវាយត្រូវក្បាល និងចុងចិញ្ចើមពីរទៅបីដៃ រួចខ្លួនក៏រត់គេចតែម្តងរឿងយ៉ាងណាខ្លួនពុំបានដឹងទៀតឡើយ លុះក្រោយមកខ្លួនបានដឹងថាឈ្មោះ [redacted] ថាច ត្រូវបានគេវាយសន្លប់យកទៅមន្ទីរពេទ្យ ហើយក្រុមជនដែលវាយខ្លួន និងឈ្មោះ [redacted] ថាច គឺខ្លួនពុំបានស្គាល់ឈ្មោះទេ គឺស្គាល់មុខ ហើយគេហៅងាវាថា អាតោ ។

ដូចនេះយោងតាមចម្លើយរបស់ជនរងគ្រោះ និងសាក្សីកន្លងមកនេះឃើញថា ការចោទប្រកាន់មកលើកូនក្តីខ្លួនក្នុងអំពើបង្ករបួសស្នាមដោយចេតនា ឃើញថា ពុំមានភស្តុតាងគ្រប់គ្រាន់ ដែលចង្អុលបង្ហាញឱ្យឃើញច្បាស់ពីសកម្មភាពរបស់កូនក្តីខ្លួន ក្នុងការចូលមកវាយលើជនរងគ្រោះឈ្មោះ [redacted] ថាច ឡើយ ។

-ផ្អែកតាមមាត្រា ៤១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល អំពើបង្ករបួសដោយចេតនា ចែងថា ជនណាវាយតប់ បណ្តាលឱ្យមានរបួស ដែលនាំឱ្យពិការអចិន្ត្រៃយ៍ ឬពិការបណ្តោះអាសន្ន ក្នុងរយៈពេលលើសពី ០៦ខែ ដោយចេតនា ត្រូវមានទោសពីបទបង្ករបួសស្នាមដោយចេតនា និងត្រូវផ្តន្ទាទោស បើផ្អែកតាមចម្លើយរបស់កូនក្តីខ្លួន នាពេលសវនាការ និងផ្អែកតាមចម្លើយជនរងគ្រោះ សាក្សី ខាងលើនេះ ខ្លួនយល់ឃើញថា ពុំមានមូលដ្ឋានគ្រប់គ្រាន់ក្នុងការចោទប្រកាន់មកលើកូនក្តីខ្លួនសោះឡើយ ។

-ចំពោះតំណាងអយ្យការសម្រេចចោទប្រកាន់មកលើកូនក្តីខ្លួនពីបទ បង្ករបួសដោយចេតនា ឃើញថាមិនមានធាតុផ្សំគ្រប់គ្រាន់នោះទេ ធ្វើឱ្យកូនក្តីខ្លួនទទួលរងភាពអយុត្តិធម៌យ៉ាងធ្ងន់ធ្ងរ ។

-បើយោងតាមមាត្រា ៣៨ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ចែងថា វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ ។

ដូចនេះក្នុងនាមខ្លួនជាមេធាវីការពារសិទ្ធិ និងតំណាងឱ្យជនជាប់ចោទឈ្មោះ [redacted] ស៊ុយ ហៅ [redacted] វ៉ាន់ស៊ុយ សូមណូមពរដល់តុលាការមេត្តា សម្រេចឱ្យកូនក្តីខ្លួនបានរួចផុតពីបទចោទ និងបញ្ឈប់ការជាប់ខ្លួនដល់កូនក្តីខ្លួនចាប់ពីពេលនេះតទៅ ។

-សំដីចុងក្រោយរបស់ជនជាប់ចោទឈ្មោះ [redacted] ស៊ុយ សំណូមពរអោយតុលាការមេត្តាសម្រេចឱ្យខ្លួនរួចផុតបទចោទប្រកាន់ ។

ក្រោយពីបានស្តាប់ចម្លើយពិរុទ្ធជន
ក្រោយពីបានស្តាប់អំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណី
ក្រោយពីបានស្តាប់អំណានចម្លើយសាក្សី
ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យពិរុទ្ធជន
ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ
ក្រោយពីបានស្តាប់សំដីចុងក្រោយរបស់ពិរុទ្ធជន
ក្រោយពីបានពិនិត្យ និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## <u>សាលាដំបូងខេត្តកណ្តាល</u>

## <u>យល់ឃើញថា</u>

-តាមពាក្យបណ្តឹងទាស់លេខ ០១៨ ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០២២ របស់មេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យឈ្មោះ [redacted] ស៊ុយ ធ្វើឡើងត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ដែលអាចឱ្យតុលាការលើកយកមកពិចារណា និងចាត់ការបាន ។



Scanned with CamScanner

-តាមចម្លើយពិរុទ្ធជនឈ្មោះ [redacted] ស៊ុយ បានឆ្លើយថា ខ្លួនសុំប្តឹងទាស់ ប៉ុន្តែខ្លួនពុំមានឯកសារដាក់ចូលបញ្ជាក់បន្ថែម ជូនតុលាការទេ នៅពេលសវនាការពិរុទ្ធជន បានឆ្លើយថា ខ្លួនមិនបានចូលរួមសកម្មភាព ឬឈ្លោះគ្នាជាមួយគេនោះទេ ។ នៅពេលកើតហេតុនោះខ្លួនក៏បាននៅកន្លែងកើតហេតុដែរ ដោយទៅហូបពងទាកូន ហើយខ្លួនក៏បានចូលទៅបន្ទប់ទឹក ពេលចេញមកវិញក៏ឃើញគេឈ្លោះគ្នាតែម្តង ខ្លួនមិនបានវ៉ៃគេច ខ្លួនទៅណានោះទេ គឺខ្លួនទៅធ្វើការសំណង់នៅខេត្ត ។

-តំណាងអយ្យការសន្និដ្ឋាន បានសន្និដ្ឋានថា ពិតជាមានភស្តុតាងគ្រប់គ្រាន់លើឈ្មោះ [redacted] ស៊ុយ បានប្រព្រឹត្តបទ **បង្ករបួសដោយចេតនា** ពិតប្រាកដមែន និងសុំរក្សាការចោទប្រកាន់តាមដីកាសន្និដ្ឋានស្ថាពរជាមូលដ្ឋាន ។

-តាមសាលក្រមព្រហ្មទណ្ឌលេខៈ **០១** (**ណ**) ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០១២ របស់សាលាដំបូងខេត្តកណ្តាល បង្ហាញឱ្យឃើញថា ជនជាប់ចោទឈ្មោះ [redacted] **ស៊ុយ** ពិតជាបានប្រព្រឹត្តបទ **បង្ករបួសដោយចេតនា** ប្រព្រឹត្តនៅភូមិស្វាយកណ្តាល ឃុំព្រែកថ្មី ស្រុកកោះធំ ខេត្តកណ្តាល កាលពីថ្ងៃទី១១ ខែតុលា ឆ្នាំ ២០០៧ ដែលត្រូវផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល និងផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] **ស៊ុយ** ដាក់ពន្ធនាគារកំណត់រយៈពេល **០១** (**មួយ**) **ឆ្នាំ** មានលក្ខណៈត្រឹមត្រូវតាមច្បាប់ ។

-ពិរុទ្ធជនឈ្មោះ [redacted] **ស៊ុយ** បានទទួលដំណឹងពីសាលក្រមកំបាំងមុខលេខៈ **០១** (**ណ**) ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០១២ របស់សាលាដំបូងខេត្តកណ្តាល តែជនជាប់ចោទរូបនេះបានប្តឹងទាស់ នឹងសាលក្រមព្រហ្មទណ្ឌ ខាងលើដោយមានភស្តុតាងថ្មីៗ ដាក់ជូនតុលាការដើម្បីពិចារណា ហើយនាពេលសវនាការចំពោះមុខជនជាប់ចោទ ជនជាប់ចោទបានសារភាពនូវអំពើរបស់ខ្លួនដែលបានប្រព្រឹត្តនៅភូមិស្វាយកណ្តាល ឃុំព្រែកថ្មី ស្រុកកោះធំ ខេត្តកណ្តាល ប្រាកដមែន ដូច្នេះតុលាការ គប្បីតម្កល់សេចក្តីសម្រេចនូវក្នុងខ្លឹមសារនៃសាលក្រមព្រហ្មទណ្ឌលេខ **០១** (**ណ**) ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០១២ ទុកជាបានការទាំងស្រុង ប៉ុន្តែកែប្រែនូវចំណុចមួយចំនួន ។

-ពិរុទ្ធជនទើបតែប្រព្រឹត្តបទល្មើសលើកដំបូង អំពើរបស់ពិរុទ្ធជនមិនបង្កនូវព្យសនកម្មធ្ងន់ធ្ងរទៅដល់សង្គម និងមិនដែលមានសាលក្រមសម្រេចផ្តន្ទាទោសជាស្ថាពរឱ្យជាប់ពន្ធនាគារក្នុងរយៈពេល ០៥ឆ្នាំ មុនពេលប្រព្រឹត្តអំពើនេះ គប្បីសាលាដំបូងពិចារណា ពីកាព្យួរទោស សម្រាប់ពិរុទ្ធជន តាមមាត្រា ១០៦ និងមាត្រា ១០៧ នៃក្រមព្រហ្មទណ្ឌ ។

-បើតុលាការពិចារណាលើការព្យួរទោសដល់ពិរុទ្ធជន ហេតុនេះគួរគប្បីតុលាការពិចារណាបញ្ឈប់ដីកាចាប់ខ្លួន លើពិរុទ្ធជនឈ្មោះ [redacted] ស៊ុយ ។

## <u>ហេតុដូច្នេះ វិនិច្ឆ័យសេចក្តី</u>

**១**-តម្កល់សាលក្រមព្រហ្មទណ្ឌលេខៈ **០១** (**យ**) ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០១២ របស់សាលាដំបូងខេត្តកណ្តាល ទុកជាបានការទាំងស្រុង ប៉ុន្តែកែប្រែនូវចំណុចផ្តន្ទាទោសលើឈ្មោះ [redacted] **ស៊ុយ** ភេទប្រុស អាយុ ២០ឆ្នាំ ដោយកំណត់ទោសដាក់ពន្ធនាគារ **០១ឆ្នាំ តែទោសនេះត្រូវព្យួរជាធម្មតា** ពីបទៈ **បង្ករបួសដោយចេតនា** ប្រព្រឹត្តនៅភូមិស្វាយកណ្តាល ឃុំព្រែកថ្មី ស្រុកកោះធំ ខេត្តកណ្តាល កាលពីថ្ងៃទី១១ ខែតុលា ឆ្នាំ២០០៧ បទល្មើសព្រហ្មទណ្ឌដែលចែងឱ្យ ផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល។

**២**-បង្គាប់ឱ្យបញ្ឈប់ចាប់ខ្លួនលើឈ្មោះ [redacted] **ស៊ុយ** ភេទប្រុស អាយុ ២០ឆ្នាំ និងបញ្ឈប់ដីកាបង្គាប់ឱ្យចាប់ខ្លួនលេខៈ **០២៦** ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០០៨ គិតចាប់ពីថ្ងៃប្រកាសសាលក្រម ។



Scanned with CamScanner

៣-សាលក្រមនេះជំនុំជំរះ និងប្រកាសជាសាធារណៈនៅថ្ងៃទី០៣ ខែមីនា ឆ្នាំ២០២២ ចំពោះមុខពិរុទ្ធជនឈ្មោះ[redacted]ស៊ុយ ។

ទុកសិទ្ធិឲ្យប្ដឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

| ក្រឡាបញ្ជីសវនាការ ហត្ថលេខា និងត្រា | ចៅក្រមជំនុំជម្រះ ហត្ថលេខា និងត្រា |
|---|---|
| [redacted] | [redacted] |

**( បានចម្លងត្រឹមត្រូវតាមច្បាប់ដើម )**

ថ្ងៃ ព្រហស្បតិ៍ ១ កើត ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

កណ្ដាល ថ្ងៃទី០៣ ខែមីនា ឆ្នាំ២០២២

**ក្រឡាបញ្ជី**

[redacted]

**បានឃើញ**

**ចៅក្រម**

[redacted]